សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

# ប្រធានបទ

## ការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣

**បង្រៀនដោយ៖ បណ្ឌិត ព្រុំ ទេវី**

**មុខវិជ្ជា ៖ វិធីសាស្ត្រស្រាវជ្រាវ**

**ថ្នាក់ P3B01**

**ឈ្មោះសមាជិកក្រុមទី១**

១. ឈិន ឆា៉ា

២. នាង ស្រីមាស

៣. ធឿន ថនសុភាវត្តី

៤. ហេង ម៉ាលីនណា

៥. សារុំ ផានរាជ

ឆ្នាំសិក្សា ២០២៥-២០២៦

# អារម្ភកថា

សូមគោរពជម្រាបសួរលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់ជំនាន់ ទាំងអស់គ្នាជាទីគោរពស្រលាញ់ រាប់អានក្រុមយើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែងជាពត់ពេក នៅពេលដែលអ្នកគ្រូ បានដាក់កិច្ចការស្រាវជ្រាវដល់ក្រុមនិស្សិតយើងខ្ញុំដែរកំពុងសិក្សាទៅលើមុខវិជ្ជា **វិធីសាស្ត្រស្រាវជ្រាវ** ធ្វើឱ្យក្រុមយើងខ្ញុំបានធ្វើការហ្វឹកហាត់ក្នុងការស្រាវជ្រាវទាក់ទងទៅ នឹង ប្រធានបទដូចបានកំណត់ជាធរមានហើយក៏សម្រាប់ជាបទពិសោធន៍ ការងារទៅថ្ងៃអនាគត។ បន្ថែមលើសពីនេះទៅទៀតនោះការដាក់កិច្ចការ នេះជាកត្តាមួយពង្រឹងចំណេះដឹងដោយសបញ្ជាក់តាមរយៈ កិច្ចការនេះសោតតែម្តង។ ហើយក៏ដូចជាក្រុមដទៃទៀតត្រូវមានស្មារតីទទួលខុសត្រូវ សាមគ្គី ការរាប់អានប្រកបភាពស្មោះត្រង់។ដើម្បីរួបរួមចំណែកចែករំលែកកិច្ចការគ្នា និងរួបរួមគ្នាសិក្សាស្រាវជ្រាវនូវកិច្ចនោះឲមានភាពកាន់តែ ប្រសើរថ្វីដ្បិតតែការធ្វើកិច្ចការអ្វីមួយតែងតែមានភាពហ្មត់ចត់ ល្អិតល្អន់បូករួមទាំងការ គិតគូរ ពិភាក្សារួម ពិនិត្យរួម ក្នុងនៃបង្កាត់និងបង្កើតជា ស្នាដៃស្រាវជ្រាវដ៏ល្អមួយ នឹងរួមទាំងកែប្រែចំណុចខ្វះខាតផងដែរ។ កិច្ចការស្រាវជ្រាវនេះគ្រាន់តែជាការបកស្រាយខ្លឹមសាររបស់ប្រធានបទ ទៅតាម សម្ថតភាព និងលទ្ធភាពផងដែរ ក្រុមយើងខ្ញុំបានធ្វើការ ស្រាវជ្រាវកន្លងមកតែប៉ុណ្ណោះ និងយោងទៅតាមឯកសារដែរមាននៅក្នុង បណ្តាញសង្គម ព្រមទាំងនៅក្នុងប្រពន្ធអ៊ិនធឺណែត និងវែបសាយផ្សេងៗទៀត។ ជាចុងក្រោយក្រុមយើងខ្ញុំរីករាយយ៉ាងក្រៃឡែងក្នុងការទទួលនៅ ការរិះគុណពីសំណាក់លោកគ្រូ សាស្ត្រាចារ្យ នឹងនិស្សិត គ្រប់រូបទាំងអស់ នូវកំហុសខុសឆ្គងទាំងឡាយដែរកើតមានឡើងដោយអចេតនាក្តី ឬចេនាក្តីពាក្យពេជន៍វគ្គឃ្លាវេយ្យាករ អក្ខារិរុទ្ធ ជាអាទ៍ ដើម្បីស្ថាបនា កែឡើងវិញឲកាន់តែប្រសើរឡើង ព្រោះតែចំណេះ ដឹង និង បទពិសោធន៍ របស់សមាជិកក្រុមយើងខ្ញុំនៅមានកម្រិតនៅឡើយ។ ក្រុមយើងខ្ញុំសូមគោរពជូនពរ សាស្ត្រចារ្យ និងនិស្សិតទាំងអស់ជួបតែសេចក្ដីសុខចម្រើននិងមានសុភមង្គលកុំបីឃ្លាតឃ្លាឡើយសូមអរគុណ។

# មាតិកា

**សេចក្តីផ្តើម** ---------- **១**
១. លំនាំបញ្ហា ---------- ១
២. ចំណូលបញ្ហា ---------- ១
៣. ចំណោទបញ្ហា ---------- ១
៤. គោលដៅនៃការស្រាវជ្រាវ ---------- ២
៥. អថេរ និងសម្មតិកម្ម ---------- ២
៦. តំបន់គោលដៅ ---------- ២
៧. ដែនកំណត់នៃការស្រាវជ្រាវ---------- ២

**ជំពូកទី១**

**ទិដ្ឋភាពទូទៅ**

១.១.និយមន័យ ---------- ៣
១.២.ប្រវត្តិនៃការបោះឆ្នោត ---------- ៣
១.៣.សារៈសំខាន់នៃការបោះឆ្នោត---------- ៤

**ជំពូកទី២**

**លក្ខខណ្ឌនិងសិទ្ធិរបស់ប្រជាពលរដ្ឋ**

២.១.លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ---------- ៥
២.២.សិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ---------- ៥
២.៣.តួនាទីរបស់គណៈកម្មាធិជាតិរៀបចំការបោះឆ្នោត(គ.ជ.ប.)---------- ៦

**ជំពូកទី៣**

**ដំណើរការនៃការបោះឆ្នោត**

៣.១.ការរៀបចំនិងការគ្រប់គ្រងការបោះឆ្នោត---------- ៨
៣.២.ដំណាក់កាលបោះឆ្នោត---------- ៩
៣.៣.ការប្រកាសលទ្ធផលនិងការត្រួតពិនិត្យ---------- ១០
**៤.សេចក្តីសន្និដ្ឋាន** ---------- **១២**
**៦.គន្ថនិទ្ទេស** ---------- i

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ចាប់ពីឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញបែបសភានិយម និងអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស បើកទូលាយឱ្យគ្រប់គណបក្សនយោបាយចូលរួមប្រកួតប្រជែងដោយសេរីនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅរៀងរាល់ ៥ឆ្នាំម្តង។ នៅក្នុងសង្គមដែលប្រកាន់យករបបប្រជាធិបតេយ្យ សេរី ពហុបក្ស ការបោះឆ្នោតគឺជាកាតព្វកិច្ច និងជាសិទ្ធិអំណាចដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាពលរដ្ឋគ្រប់រូប។ តាមរយៈការបោះឆ្នោត ពលរដ្ឋមិនត្រឹមតែបំពេញតួនាទីជាម្ចាស់ប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមពង្រឹងស្ថាប័នរដ្ឋឱ្យមានភាពស្របច្បាប់ និងឆ្លុះបញ្ចាំងពីភាពចាស់ទុំនៃស្មារតីទទួលខុសត្រូវរបស់ជាតិសាសន៍មួយ។

## ២. ចំណូលបញ្ហា

ការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០២៣ គឺជាព្រឹត្តិការណ៍នយោបាយសំខាន់មួយ ដែលបង្ហាញពីដំណើរការប្រជាធិបតេយ្យ និងសិទ្ធិពលរដ្ឋក្នុងការជ្រើសរើសអ្នកតំណាងរបស់ខ្លួន។ ការបោះឆ្នោតនេះជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ក្រោមការរៀបចំរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ក្នុងការបោះឆ្នោតនេះ មានគណបក្សនយោបាយជាច្រើនចូលរួមប្រកួតប្រជែង ប៉ុន្តែគណបក្សដែលទទួលបានអាសនៈភាគច្រើនគឺ គណបក្សប្រជាជនកម្ពុជា (CPP)។

## ៣. ចំណោទបញ្ហា

### ក. ចំណោទបញ្ហាសំខាន់

- តើដំណើរការនៃការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

### ខ. ចំណោទបញ្ហាបន្ទាប់បន្សំ

- តើអ្វីទៅជាការបោះឆ្នោតហើយការបោះឆ្នោតមានសារៈសំខាន់យ៉ាងណា?
- នៅពេលប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតត្រូវមានលក្ខខណ្ឌបែបណា និងទទួលបានសិទ្ធិអ្វីខ្លះ?
- តើការបោះឆ្នោតប្រព្រឹត្តទៅយ៉ាងណានិងមានការគ្រប់គ្រងដូចម្តេចដែរ?

## ៤. គោលដៅនៃការស្រាវជ្រាវ

- សិក្សាអំពីការបោះឆ្នោត និងសារៈសំខាន់នៃការបោះឆ្នោត។
- ធ្វើការកំណត់អំពីលក្ខខណ្ឌនៅពេលដែលប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតនិង សិទ្ធិដែលទទួលបាន។
- សិក្សាអំពីដំណើរការប្រព្រឹត្តទៅនិងការគ្រប់គ្រងនៃការបោះឆ្នោត។

## ៥. អថេរនិងសម្មតិកម្ម

- អថេរមិនអាស្រ័យ៖ បោះឆ្នោតជ្រើសរើសអ្នកដឹកនាំ
- អថេរអាស្រ័យ៖ ក្បាលម៉ាស៊ីនដឹកនាំប្រទេស
- អថេរខាងក្រៅ៖ អ្នកសង្កេតការណ៍បោះឆ្នោត
- អថេរអន្តរាគមន៍៖ គ.ជ.ប រៀបចំនិងគ្រប់គ្រងការបោះឆ្នោត

## ៦. តំបន់គោលដៅនិងក្រុមគោលដៅ

- តំបន់គោលដៅ៖ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតទូទាំងប្រទេសកម្ពុជា។

- ក្រុមគោលដៅ៖ ប្រជាពលរដ្ឋអាយុចាប់ពី ១៨ ឆ្នាំឡើងទៅដែលមានសិទ្ធិបោះឆ្នោត គណបក្សនយោបាយ បេក្ខជនមន្ត្រីរៀបចំបោះឆ្នោត និងអ្នកសង្កេតការណ៍។

## ៧. ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវសម្រាប់ប្រធានបទនេះក្រុមយើងខ្ញុំផ្តោតលើ ការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០២៣ ជាគោលដៅសំខាន់ ដើម្បីវិភាគដំណើរការ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ វារួមបញ្ចូលការសិក្សាដំណាក់កាលនៃការរៀបចំការបោះឆ្នោត ចាប់ពីការចុះបញ្ជីឈ្មោះបោះឆ្នោត ការរៀបចំការបោះឆ្នោតនៅកន្លែងបោះឆ្នោត និងការប្រកាសលទ្ធផល។ ការស្រាវជ្រាវក៏ពិនិត្យ តំបន់គោលដៅ និងក្រុមគោលដៅ ដែលមានការចូលរួម ដូចជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រជាពលរដ្ឋអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ បេក្ខជន គណបក្សនយោបាយ មន្ត្រីរៀបចំបោះឆ្នោត និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ។ ប្រភពព័ត៌មានសំខាន់ៗត្រូវបានប្រើ ឯកសារ ផ្លូវការ របាយការណ៍ និងព័ត៌មានអនឡាញ ដើម្បីធានាថាវិស័យស្រាវជ្រាវមានភាពត្រឹមត្រូវ និងច្បាស់លាស់។ ចំណុចស្រាវជ្រាវនេះមិនទាក់ទងនឹង ការបោះឆ្នោតឆ្នាំផ្សេងៗ ឬប្រទេសផ្សេង ដោយផ្តោតលើការវិភាគស្ថានភាព និងដំណើរការបោះឆ្នោតឆ្នាំ ២០២៣ តែម្តង។

# ជំពូកទី១

# ទិដ្ឋភាពទូទៅ

## ១.១. និយមន័យ

ការបោះឆ្នោត គឺជាគោលការណ៍គ្រឹះមួយនៃលទ្ធិប្រជាធិបតេយ្យដែលប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីជ្រើសរើសតំណាងដែលខ្លួនពេញចិត្តឲ្យដឹកនាំកិច្ចការនយោបាយរបស់រដ្ឋទាំងមូលក្នុងនោះមានសភាដែលតំណាងឲ្យអង្គការនីតិបញ្ញត្តិ និងរដ្ឋាភិបាលដែលតំណាងឲ្យអង្គការនីតិប្រតិបត្តិ ហើយការបោះឆ្នោតនេះធ្វើឡើងក្នុងចន្លោះពេលកំណត់នីមួយៗ តាមរយៈសន្លឹកឆ្នោត មួយ ឬសម្លេងឆ្នោតមួយ។[1]

ឬ ការបោះឆ្នោត គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ការបោះឆ្នោតជាយន្ត ការសម្រាប់ជ្រើសរើសថ្នាក់ដឹកនាំគ្រប់ថ្នាក់រដ្ឋបាល នៃសង្គមប្រជាធិបតេយ្យការគ្រប់គ្រងប្រទេសតាមបែប ប្រជាធិបតេយ្យ ផ្តល់អំណាចជាធំដល់ប្រជាពលរដ្ឋនៅក្នុងការ សម្រេចចិត្តលើកិច្ចការធំៗរបស់ប្រទេសជាតិតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។[2]

## ១.២.ប្រវត្តិនៃការបោះឆ្នោត

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ កម្ពុជាជួបសង្គ្រាមស៊ីវិលជាង ២០ ឆ្នាំ រហូតដល់ភាគីជម្លោះចុះកិច្ចព្រមព្រៀងសន្តិភាពនៅឆ្នាំ១៩៩១។ ការបោះឆ្នោតជាតិលើកទី១ ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៩៣ ដោយ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) សហការជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ដោយមានអត្រាចូលរួមខ្ពស់ ទោះបីមានអស្ថេរភាពខ្លះៗក៏ដោយ ហើយបង្កើតរដ្ឋាភិបាលចម្រុះ ព្រោះគ្មានគណបក្សណាមានសំឡេង ២/៣ ដាច់ខាត។ បន្ទាប់មកប្រព័ន្ធនយោបាយត្រូវបានពង្រីកដោយបង្កើតព្រឹទ្ធសភា និងរៀបចំការបោះឆ្នោតថ្នាក់មូលដ្ឋាន (ឃុំ-សង្កាត់) ចាប់ពីឆ្នាំ២០០២ និងការបោះឆ្នោតថ្នាក់រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ចាប់ពីឆ្នាំ២០០៩។ ការបោះឆ្នោតជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាបន្តបន្ទាប់ ប៉ុន្តែជាញឹកញាប់កើតមានភាពជាប់គាំងនយោបាយក្រោយការប្រកាសលទ្ធផល ដែលបណ្តាលឱ្យត្រូវបង្កើតរដ្ឋាភិបាលចម្រុះ និងធ្វើសម្បទាននយោបាយ។ ក្រោយការបោះឆ្នោតឆ្នាំ២០១៣ មានកំណែទម្រង់សំខាន់ៗលើសភាច្បាប់បោះឆ្នោត និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយស្ថាប័ននេះត្រូវបានកំណត់ជាស្ថាប័នកំពូលក្នុងរដ្ឋធម្មនុញ្ញ និងមានច្បាប់អង្គការផ្ទាល់ខ្លួន ដើម្បីធានាប្រសិទ្ធភាព និងភាពឯករាជ្យក្នុងការរៀបចំការបោះឆ្នោត។

[1] ដកស្រង់ចេញពីសៀវភៅនីតិរដ្ឋម្មនុញ្ញ បោះពុម្ពលើកទី៣ ឆ្នាំ២០២១ ទំព័រទី៦៦

[2] ដកស្រង់ចេញពីប្រសាសន៍របស់លោក **ប្រាជ្ញ ចន្ទ**

## ១.៣. សារៈសំខាន់នៃការបោះឆ្នោត

- ➢ សារៈសំខាន់នៃការបោះឆ្នោតមានដូចជា៖
- ○ **ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ**
- - **សិទ្ធិសម្រេចចិត្ត:** ការបោះឆ្នោតផ្តល់ឱកាសឱ្យប្រជាពលរដ្ឋម្នាក់ៗមានសិទ្ធិស្មើគ្នាក្នុងការជ្រើសរើសតំណាងដែលខ្លួនពេញចិត្ត ដើម្បីមកដឹកនាំរដ្ឋបាលគ្រប់កម្រិត។
- - **ការបញ្ចេញមតិ:** វាជាវេទិកាសម្រាប់ពលរដ្ឋក្នុងការបង្ហាញពីទស្សនៈ ក្តីសង្ឃឹម និងតម្រូវការរបស់ពួកគេចំពោះរដ្ឋាភិបាល។
- - **កាតព្វកិច្ចពលរដ្ឋ:** ការទៅបោះឆ្នោតបង្ហាញពីការទទួលខុសត្រូវ និងការបំពេញកាតព្វកិច្ចជាពលរដ្ឋល្អក្នុងសង្គម។
- ○ **ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ច**
- - **គណនេយ្យភាព:** ការបោះឆ្នោតបង្ខំឱ្យអ្នកនយោបាយត្រូវទទួលខុសត្រូវចំពោះមុខម្ចាស់ឆ្នោត ប្រសិនបើពួកគេមិនធ្វើតាមការសន្យា ពលរដ្ឋអាចផ្លាស់ប្តូរពួកគេតាមរយៈការបោះឆ្នោតអាណត្តិក្រោយ។
- - **ការផ្ទេរអំណាចដោយសន្តិវិធី:** វាជាយន្តការដែលមានតម្លាភាព និងយុត្តិធម៌សម្រាប់ការផ្ទេរអំណាចពីអាណត្តិមួយទៅអាណត្តិមួយទៀត ដោយគ្មានអំពើហិង្សា។
- - **ភាពស្របច្បាប់:** រដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ទទួលបាននូវភាពស្របច្បាប់ និងការទទួលស្គាល់ទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិ។
- ○ **ការអភិវឌ្ឍសង្គម និងគោលនយោបាយ**
- - **ការជ្រើសរើសគោលនយោបាយ:** អ្នកបោះឆ្នោតអាចជ្រើសរើសបក្សនយោបាយណាដែលមានកម្មវិធីនយោបាយត្រូវនឹងតម្រូវការរបស់ពួកគេ ដូចជាបញ្ហាសេដ្ឋកិច្ច ការអប់រំ ឬសុខាភិបាល។
- - **ការចូលរួមរបស់យុវជន:** ការបោះឆ្នោតផ្តល់អំណាចដល់យុវជនក្នុងការកំណត់អនាគតដែលពួកគេចង់បានសម្រាប់ខ្លួនឯង និងសហគមន៍។

# ជំពូកទី២

# លក្ខខណ្ឌនិងសិទ្ធិរបស់ប្រជាពលរដ្ឋ

## ២.១.លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យណាមួយក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត នៅ ការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួន ត្រូវចុះឈ្មោះបោះឆ្នោត ។
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ដែលនៅមានសុពលភាព) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។
- មានសញ្ជាតិខ្មែរ ។
- មានអាយុ ១៨ ឆ្នាំឡើងទៅ គឺកើតមុន ឬកើតត្រឹមថ្ងៃទី១ ខែសីហា ឆ្នាំ២០០១ ។
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួន ត្រូវចុះឈ្មោះបោះឆ្នោត ។
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅ កន្លែងណាមួយក្នុងឃុំ សង្កាត់ ។

**ត្រូវចាំថា៖**

១.ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតតែមួយគត់ ។

២.ក្នុងករណីប្រជាពលរដ្ឋណាម្នាក់ ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមាន បំណងសុំប្តូរការិយាល័យបោះឆ្នោត សូមប្រាប់ប្រធានក្រុមចុះឈ្មោះបោះឆ្នោត ។

៣.ចំពោះជនណាដោយទុច្ចរិតព្យាយាម ចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន )រៀល ដោយ គ.ជ.ប លើកលែងតែមានការអនុញ្ញាតដោយច្បាប់ ។[3]

## ២.២.សិទ្ធិនិងភាតព្វកិច្ចរបស់ប្រជាពលរដ្ឋ

សិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតនៅកម្ពុជាមានចែងក្នុង រដ្ឋធម្មនុញ្ញដោយពលរដ្ឋអាយុចាប់ពី ១៨ ឆ្នាំឡើងមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជន។ ពួកគេមាន

[3] ដកស្រង់ចេញពីវេបសាយ សៀវភៅសម្រាប់អ្នកចុះឈ្មោះបោះឆ្នោត ថ្ងៃទី០២ មីនា ២០២៦

កាតព្វកិច្ចត្រូវទៅបោះឆ្នោតដើម្បីជ្រើសរើសតំណាង និងគោរពច្បាប់ដើម្បីលើកកម្ពស់ប្រជាធិបតេយ្យ ការចូលរួមនេះជាការបំពេញសិទ្ធិនិងកាតព្វកិច្ចក្នុងការកសាងជាតិ។

**ក.សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត (សិទ្ធិសកម្ម និងអកម្ម)**

- **សិទ្ធិបោះឆ្នោត៖** ពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាផ្សេងៗទៀត។
- **សិទ្ធិឈរឈ្មោះ៖** មានសិទ្ធិឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោត។
- **សិទ្ធិសេរីភាព៖** មានសិទ្ធិបង្កើត ឬចូលរួមជាមួយគណបក្សនយោបាយ និងសមាគមន៍នានាដើម្បីទាមទារឲ្យរដ្ឋាភិបាលធ្វើតាមឆន្ទៈរបស់ខ្លួន។

**ខ.កាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត**

- **កាតព្វកិច្ចចំពោះជាតិ៖** ចូលរួមចំណែកកសាងប្រទេសជាតិ តាមរយៈការបោះឆ្នោតដើម្បីការពារមាតុភូមិ។
- **គោរពច្បាប់៖** គោរពរដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ។
- **ចូលរួមចំណែក៖** ចូលរួមដឹងលឺ និងជាចំណែកក្នុងកិច្ចការរដ្ឋាភិបាល។

## ២.៣.តួនាទីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានតួនាទីស្នូលជាស្ថាប័នឯករាជ្យ និងអព្យាក្រឹតក្នុងការរៀបចំចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោតគ្រប់កម្រិត (ជាតិ និងក្រោមជាតិ) នៅកម្ពុជាឱ្យមានតម្លាភាព សច្ចៈនិងយុត្តិធម៌។ គ.ជ.ប. មានភារកិច្ចចុះឈ្មោះអ្នកបោះឆ្នោតរៀបចំបញ្ជីឈ្មោះ រៀបចំយុទ្ធនាការ និងប្រកាសលទ្ធផល។

តួនាទី និងភារកិច្ចសំខាន់ៗរបស់ គ.ជ.ប. រួមមាន៖

- **រៀបចំ និងចាត់ចែងការបោះឆ្នោត៖** ធ្វើផែនការ រៀបចំ និងចាត់ចែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, ការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំ-សង្កាត់, និងការបោះឆ្នោតផ្សេងៗទៀតឱ្យស្របតាមច្បាប់។
- **ចុះឈ្មោះបោះឆ្នោត៖** រៀបចំការចុះឈ្មោះបោះឆ្នោតពិនិត្យបញ្ជីឈ្មោះ និងរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជាប្រចាំជារៀងរាល់ឆ្នាំ។
- **គ្រប់គ្រងយុទ្ធនាការ៖** រៀបចំ និងគ្រប់គ្រងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ព្រមទាំងពិនិត្យ និងសម្រេចលើការចុះឈ្មោះគណបក្សនយោបាយ និងបញ្ជីបេក្ខជន។
- **ត្រួតពិនិត្យ និងសម្រេច៖** ត្រួតពិនិត្យការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលផ្លូវការ។

- **ដោះស្រាយវិវាទ៖** ដោះស្រាយពាក្យបណ្ដឹងតវ៉ាដែលទាក់ទងនឹងដំណើរការបោះឆ្នោត និងបទបញ្ជាផ្ទៃក្នុង។
- **អប់រំ និងផ្សព្វផ្សាយ៖** ផ្សព្វផ្សាយព័ត៌មានអប់រំអ្នកបោះឆ្នោត និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការបោះឆ្នោត។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុម័តសម្រេចបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ដោយសំឡេងពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។ ករណីមិនមានកូរ៉ុម ឬ/និងសំឡេងគ្រប់ចំនួនសម្រាប់អនុម័តតាមមតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការកោះប្រជុំជាលើកទី២ នៅថ្ងៃបន្ទាប់ជាបន្ទាន់ ហើយកូរ៉ុម និងសំឡេងសម្រាប់អនុម័ត ត្រូវមានចំនួនភាគច្រើនដាច់ខាតនៃសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ក្រៅពីបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុម័តសម្រេច ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ករណីមានសំឡេងស្មើគ្នាក្នុងការអនុម័តលើបញ្ហាណាមួយ សំឡេងរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឧត្តមានុភាព ។ ក្នុងករណីដំណើរការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជាប់គាំងដោយសារមិនមានកូរ៉ុម ឬមិនមានសំឡេងគ្រប់គ្រាន់ ដើម្បីអនុម័តបញ្ហាណាមួយ រដ្ឋសភាត្រូវធ្វើការសម្រេចរំសាយសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានបញ្ហានោះ ហើយត្រូវរៀបចំសមាសភាពថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។រាល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីការធ្វើសេចក្ដីសម្រេច ។

# ជំពូកទី៣
# ដំណើរការនៃការបោះឆ្នោត

## ៣.១.ការរៀបចំនិងការគ្រប់គ្រងការបោះឆ្នោត

ការរៀបចំ និងការគ្រប់គ្រងការបោះឆ្នោត ជាដំណើរការសំខាន់ក្នុងប្រព័ន្ធប្រជាធិបតេយ្យ ដើម្បីធានាថា ការជ្រើសរើសតំណាងរាស្ត្រ ឬមេដឹកនាំ មានភាពស្មោះត្រង់ យុត្តិធម៌ និងតម្លាភាព។ នៅក្នុងប្រទេសកម្ពុជា ការរៀបចំការបោះឆ្នោតស្ថិតក្រោមការទទួលខុសត្រូវរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)។

**ក.ការរៀបចំការបោះឆ្នោត** មានជំហានសំខាន់ៗដូចជា៖

- កំណត់កាលបរិច្ឆេទបោះឆ្នោត
- ចុះឈ្មោះអ្នកបោះឆ្នោត
- ចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជន
- រៀបចំបញ្ជីឈ្មោះបោះឆ្នោត
- រៀបចំទីតាំងការិយាល័យបោះឆ្នោត
- បោះពុម្ពសន្លឹកឆ្នោត និងឯកសារពាក់ព័ន្ធ

**ខ.ការគ្រប់គ្រងការបោះឆ្នោត** ផ្តោតលើ៖

- ត្រួតពិនិត្យដំណើរការបោះឆ្នោតឱ្យបានត្រឹមត្រូវ
- ថែរក្សាសុវត្ថិភាព និងសន្តិសុខនៅការិយាល័យបោះឆ្នោត
- គ្រប់គ្រងការរាប់សន្លឹកឆ្នោត
- ប្រកាសលទ្ធផលជាផ្លូវការ
- ដោះស្រាយពាក្យបណ្តឹង និងជម្លោះ

**គ.គោលការណ៍សំខាន់ៗ**

- សេរីភាព និងសមភាព
- សម្ងាត់ក្នុងការបោះឆ្នោត
- តម្លាភាព
- ឯករាជ្យភាព

ការរៀបចំ និងការគ្រប់គ្រងការបោះឆ្នោតល្អ នឹងជួយបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋ និងធានាថាប្រទេសមានស្ថិរភាពនយោបាយ និងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៣.២.ដំណាក់កាលបោះឆ្នោត

ដំណាក់កាលនៃការបោះឆ្នោតនៅកម្ពុជាមាន ៣ ដំណាក់កាលសំខាន់ៗគឺ៖ ១. **មុនពេលបោះឆ្នោត** (**ចុះឈ្មោះ, ឃោសនា**) ២. **អំឡុងពេលបោះឆ្នោត** (**ថ្ងៃបោះឆ្នោត, សម្ងាត់**) និង ៣. **ក្រោយពេលបោះឆ្នោត** (**រាប់សន្លឹកឆ្នោត, ប្រកាសលទ្ធផល**)។ ដំណើរការទាំងនេះរៀបចំដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តាមរយៈគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស។

**ក. ដំណាក់កាលត្រៀមរៀបចំ (មុនពេលបោះឆ្នោត)**

នេះជាដំណាក់កាលវែងជាងគេ ដើម្បីធានាថាការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន៖

- ការចុះឈ្មោះបោះឆ្នោត៖ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះអ្នកបោះឆ្នោតថ្មីជារៀងរាល់ឆ្នាំ ដើម្បីរៀបចំបញ្ជីបោះឆ្នោតផ្លូវការ។
- ការចុះបញ្ជីគណបក្ស និងបេក្ខជន៖ គណបក្សនយោបាយត្រូវចុះបញ្ជីនៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។
- ការឃោសនាបោះឆ្នោត៖ រយៈពេលដែលគណបក្សនយោបាយបង្ហាញគោលនយោបាយ និងស្វែងរកការគាំទ្រ (ជាទូទៅមានរយៈពេល ២១ ថ្ងៃ មុនថ្ងៃបោះឆ្នោត)។

**ខ. អំឡុងពេលបោះឆ្នោត (ថ្ងៃបោះឆ្នោត, សម្ងាត់)**

សកម្មភាពសំខាន់ៗដែលកើតឡើងនៅការិយាល័យបោះឆ្នោត៖

- ការបើកការិយាល័យ៖ ចាប់ផ្តើមនៅម៉ោង ៧:០០ ព្រឹក។
- ដំណើរការបោះឆ្នោត៖
  ១.អ្នកបោះឆ្នោតបង្ហាញអត្តសញ្ញាណប័ណ្ណ (អ.ខ)។
  ២.ទទួលសន្លឹកឆ្នោត និងចូលទៅក្នុងបន្ទប់សម្ងាត់ដើម្បីគូសលើគណបក្សដែលពេញចិត្ត។
  ៣.យកសន្លឹកឆ្នោតដាក់ក្នុងហិប និងជ្រលក់ម្រាមដៃក្នុងទឹកខ្មៅជ្រលក់មិនលាងជ្រះ។

**គ. ក្រោយពេលបោះឆ្នោត (រាប់សន្លឹកឆ្នោត, ប្រកាសលទ្ធផល)**

ការប្រមូលទិន្នន័យ និងការប្រកាសលទ្ធផល៖

- ការរាប់សន្លឹកឆ្នោត៖ ធ្វើឡើងភ្លាមៗនៅតាមការិយាល័យបោះឆ្នោត បន្ទាប់ពីការបោះឆ្នោតត្រូវបានបិទ (ម៉ោង ៣:០០ រសៀល)។

- ការបូកសរុបលទ្ធផល៖ លទ្ធផលត្រូវបានបញ្ជូនពីថ្នាក់ឃុំ/សង្កាត់ ទៅខេត្ត និងទៅថ្នាក់ជាតិ។
- ការប្រកាសលទ្ធផល៖ គ.ជ.ប នឹងប្រកាសលទ្ធផលបណ្ដោះអាសន្ន រួចបន្តទៅការដោះស្រាយបណ្ដឹង (បើមាន) មុននឹងប្រកាសលទ្ធផលផ្លូវការ។

## ៣.៣.ការប្រកាសលទ្ធផលនិងការត្រួតពិនិត្យ

បន្ទាប់ពីបិទការិយាល័យបោះឆ្នោតនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣ នៅតាមការិយាល័យបោះឆ្នោតនីមួយៗ មន្ត្រីការិយាល័យរៀបចំការបោះឆ្នោតទាំងអស់ រៀបចំរាប់សន្លឹកឆ្នោតនិងធ្វើកំណត់ហេតុនៃការបោះឆ្នោត រួចហើយបញ្ជូនទៅគណៈកម្មាធិការរាជធានីខេត្តរៀបចំការបោះឆ្នោត។ គណៈកម្មាធិការរាជធានីខេត្តរៀបចំការបោះឆ្នោតនេះដឹកជញ្ជូនសន្លឹកឆ្នោត និងធ្វើកំណត់ហេតុដែលបានមកពីការិយាល័យបោះឆ្នោតនីមួយៗ បន្តទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលដែលគេបានផ្ញើរមកពីការិយាល័យបោះឆ្នោតផ្សេងៗនៅទូទាំងប្រទេស។ ក្រោយពីបានពិនិត្យលទ្ធផល កំណត់ហេតុ និងដោះស្រាយបណ្ដឹងតវ៉ាពីគណបក្សនានាចប់សព្វគ្រប់រួចហើយ ទើបគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំការប្រកាលទ្ធផលនៃការបោះឆ្នោតនោះជាផ្លូវការ។

### ក.ការប្រកាសលទ្ធផលបោះឆ្នោត

ដំណើរការប្រកាសលទ្ធផលបានប្រព្រឹត្តទៅតាមលំដាប់លំដោយ ចាប់ពីថ្នាក់ក្រោមរហូតដល់ថ្នាក់ជាតិ៖

- ការប្រកាសលទ្ធផលបណ្ដោះអាសន្ននៅគ្រប់គណៈកម្មាធិការរៀបចំការបោះឆ្នោត (គ.រ.ប.) ឃុំ-សង្កាត់៖ ភ្លាមៗបន្ទាប់ពីបិទការិយាល័យបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ គ.រ.ប. ឃុំ-សង្កាត់ទាំងអស់បានចាប់ផ្ដើមរាប់សន្លឹកឆ្នោត ហើយប្រកាសលទ្ធផលជាបណ្ដោះអាសន្ននៅកន្លែងបោះឆ្នោត ដោយមានការចូលរួមពីភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងអ្នកសារព័ត៌មាន។
- ការប្រកាសលទ្ធផលផ្លូវការដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)៖ គ.ជ.ប. បានបន្តប្រកាសលទ្ធផលបណ្ដោះអាសន្នតាមរយៈបណ្ដាញផ្សព្វផ្សាយនានា និងនៅទីស្នាក់ការកណ្ដាល។ ក្រោយពេលទទួលបានរបាយការណ៍លទ្ធផលពីគ្រប់ឃុំ-សង្កាត់ និងពិនិត្យផ្ទៀងផ្ទាត់រួច គ.ជ.ប. បានប្រកាសលទ្ធផលជាផ្លូវការ (បឋម) នៅថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២៣។ លទ្ធផលនេះបានបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជាទទួលបាន ១២០ អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៥ អាសនៈ។[4]

[4] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)សេចក្ដីប្រកាសព័ត៌មានស្ដីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ឆ្នាំ២០២៣,គេហទំព័រ គ.ជ.ប.(www.nec.gov.kh), ថ្ងៃទី៥ខែសីហាឆ្នាំ២០២៣

**ខ.ការត្រួតពិនិត្យ និងវាយតម្លៃ**

ការត្រួតពិនិត្យធ្វើឡើងដោយស្ថាប័នពាក់ព័ន្ធ ភាគីជាតិ និងអន្តរជាតិ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងតម្លាភាព

- **ការត្រួតពិនិត្យផ្ទៃក្នុង** ៖ ភ្នាក់ងារគណបក្សនយោបាយទាំងអស់ដែលឈរឈ្មោះបោះឆ្នោតមានវត្តមានពេញលេញនៅតាមការិយាល័យបោះឆ្នោតនីមួយៗ ដើម្បីតាមដានការរាប់សន្លឹកឆ្នោត និង ចុះហត្ថលេខាលើ កំណត់ហេតុ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) បានដំណើរការយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនគ្រប់ជាន់ថ្នាក់។
- **ការត្រួតពិនិត្យពីសំណាក់អង្គការសង្គមស៊ីវិលជាតិ** ៖ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ស.យ.ក.) បានចេញរបាយការណ៍សង្កេតការណ៍របស់ខ្លួន ដោយវាយតម្លៃថា ការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា និងគ្មានការបំភិតបំភ័យអ្នកបោះឆ្នោត បើទោះបីជាមានការកត់សម្គាល់ខ្លះៗពីបញ្ហាបច្ចេកទេសក៏ដោយ។
- **ការត្រួតពិនិត្យពីសំណាក់សហគមន៍អន្តរជាតិ** ៖ គណៈប្រតិភូអ្នកសង្កេតការណ៍អន្តរជាតិដែលរួមមានតំណាងអាស៊ាន (ក្រុមអ្នកសង្កេតការណ៍មកពីបណ្តាប្រទេសជាសមាជិកអាស៊ាន) និងបណ្តាប្រទេសផ្សេងទៀត បានចូលរួមសង្កេតការណ៍។ ជាទូទៅ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិទាំងនេះបានវាយតម្លៃថា ការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន ស្ងប់ស្ងាត់ និងមានសណ្តាប់ធ្នាប់ល្អ។[5]

[5] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ឆ្នាំ២០២៣,គេហទំព័រ គ.ជ.ប.(www.nec.gov.kh), ថ្ងៃទី៥ខែសីហាឆ្នាំ២០២៣។

# សេចក្តីសន្និដ្ឋាន

ការបោះឆ្នោតពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ប្រជាជនក៏ដូចជាប្រទេសជាតិមួយក្នុងការឈរជើងឲ្យមានសុខសន្តិភាព មានការរីកចម្រើន និងការអភិវឌ្ឍសេដ្ឋកិច្ច ហេតុនេះគេផ្តល់សិទ្ធដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសនូវក្បាលម៉ាស៊ីនដឹកនាំ និងគ្រប់គ្រងប្រទេសដែលពួកគេស្រឡាញ់ និងពេញចិត្ត។ រាល់ការបោះឆ្នោតប្រជាជននិងទទួលបានការផ្សព្វផ្សាយ ការណែនាំពីរបៀបបោះឆ្នោតឲ្យបានត្រឹមត្រូវ លក្ខខណ្ឌនៃការបោះឆ្នោត ការរក្សានូវការសម្ងាត់ ក៏ដូចជាការចេញលទ្ធផលជាដើម ដែលធានាបានឲ្យបាននូវតម្លាភាព សុក្រឹតភាព ជូនដល់ប្រជាពលរដ្ឋ។

# គន្ថនិទេស

១.ដកស្រង់ចេញពីគេហទំព័រ **អង្គការទិន្នន័យអំពីការអភិវឌ្ឍ** ថ្ងៃទី០១ មីនា ២០២៦ ការបោះឆ្នោត | Open Development Cambodia (ODC)

២.ដកស្រង់ចេញពីគេហទំព័រ**វិគីភីឌាភាសាខ្មែរ**ស្តីពីការបោះឆ្នោតនៅកម្ពុជា (៥.ដំណើរការបោះឆ្នោះ)

៣.ដកស្រង់ចេញពីគេហទំព័រ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)** ថ្ងៃទី០៦ មីនា ២០២៦

៤. ដកស្រង់ចេញពីគេហទំព័រ **បទយកការណ៍៖គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គ្រោងនឹងបោះពុម្ពសន្លឹកឆ្នោតជាង១៣លានសន្លឹកសម្រាប់បម្រើឱ្យការបោះឆ្នោតខាងមុខ**